សារអំពីព័ត៌មានថ្នាំបង្ការ

# ថ្នាំបង្ការជំងឺស្វិតដៃជើង

***អ្វីដែលអ្នកត្រូវដឹង***

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis.

សារអំពីព័ត៌មានថ្នាំចាក់បង្ការមួយចំនួន មានសរសេរជាភាសាអេស្ប៉ាញ និងភាសាដទៃទៀ ។ សូមទស្សនា គេហទំព័រ www.immunize.org/vis.

## 1 តើអ្វីជាជំងឺស្វិតដៃជើង?

ស្វិតដៃជើង ជាជំងឺដែលបណ្តាលពីវីរុស ។ មេរោគនេះចូលក្នុងខ្លួនមនុស្សតាមមាត់ ។ ជាទូទៅវាមិនបង្ករឲ្យកើតជំងឺធ្ងន់ធ្ងរឡើយ ។ តែពេលខ្លះ វាបណ្តាលឲ្យងាប់អវយវៈ (មិនអាចកម្រើកដៃ ឬជើងបាន) ហើយវាអាចបណ្តាលឲ្យកើតជំងឺ រលាកស្រោមខួរក្បាល (រមាស់សរសៃខួរ ក្បាល) ។ វាអាចសម្លាប់អ្នកជំងឺបាន ជាទូទៅវាធ្វើឲ្យងាប់សាច់ដុំ សម្រាប់ប្រើក្នុងការដក ដង្ហើម ។

ជំងឺស្វិតដៃជើង ធ្លាប់ជាជំងឺធម្មតា នៅសហរដ្ឋអាមេរិក ។ វាធ្វើឲ្យអ្នកជំងឺពិការ និងសម្លាប់មនុស្សអស់រាប់ពាន់នាក់ ក្នុងមួយឆ្នាំ នៅមុនពេលអ្នកវិទ្យាសាស្ត្រ រកឃើញថ្នាំបង្ការ ។

## 2 ហេតុអ្វីត្រូវចាក់ថ្នាំបង្ការ?

**ប្រវត្តិ ៖** កាលដែលមានការរាតត្បាតគ្រប់ទីកន្លែងនៃជំងឺស្វិតដៃជើង នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ 1916 បានសម្លាប់មនុស្សអស់ចំនួន 6,000 នាក់ ហើយធ្វើឲ្យមនុស្សពិការជាង 27,000 ទៀត ។ នៅដើមទសវត្សរ៍ឆ្នាំ 1950 មានជំងឺស្វិតដៃជើងកើតឡើងជាង 25,000 ករណី ត្រូវបានរាយការណ៍ថាបានកើតឡើងជារៀងរាល់ឆ្នាំ ។ ការចាក់ថ្នាំបង្ការជំងឺស្វិតដៃជើង បានចាប់ផ្តើមក្នុងឆ្នាំ 1955 ។ ចូលមកដល់ឆ្នាំ 1960 ការកើតជំងឺនេះ បានរាយការណ៍មកថា បានថយចុះប្រហែល 3,000 ករណី ហើយមកដល់ឆ្នាំ 1979 មានរបាយការណ៍ថា មានប្រហែល 10 ករណីប៉ុណ្ណោះបានកើតឡើង ។ ភាពជោគជ័យនៃការចាក់ថ្នាំបង្ការជំងឺស្វិតដៃជើង នៅសរអា និងនៅប្រទេសដទៃទៀត បានបង្ករឲ្យមានការព្យាយាម នៅទូទាំងពិភពលោក ក្នុងការលប់បំបាត់ជំងឺនេះ។

**បច្ចុប្បន្ន ៖** ជំងឺស្វិតដៃជើង ត្រូវបានលុបបំបាត់ចេញអស់ពីសហរដ្ឋអាមេរិកហើយ ។ តែជំងឺនេះ បន្តស្ថិតនៅជាជំងឺធម្មតានៅឡើយ នៅតាមប្រទេសមួយចំនួន ក្នុងពិភពលោក ។ វាអាចមាន មនុស្សតែម្នាក់ប៉ុណ្ណោះដែលឆ្លងវីរុសជំងឺស្វិតដៃ ជើងពីប្រទេសដទៃយកមកចម្លងក្នុងស្រុកយើង ប្រសិនបើយើងមិនបានចាក់ថ្នាំបង្ការទេនោះ ។ ប្រសិនបើសេចក្តីព្យាយាម លុបបំបាត់ជំងឺនេះ ពីពិភពលោកមានភាពជោគជ័យនោះ នៅថ្ងៃណា មួយ មនុស្សយើងនឹងលែងត្រូវការថ្នាំបង្ការទៀត ហើយ ។ តែមុនថ្ងៃនោះចូលមកដល់ យើងនៅតែ ត្រូវចាក់ថ្នាំបង្ការឲ្យកូនៗយើងជានិច្ច ។

## 3 នរណាគួរចាក់ថ្នាំបង្ការជំងឺស្វិតដៃជើង និងត្រូវចាក់នៅពេលណា?

IPV ជាថ្នាំចាក់ ដែលត្រូវចាក់តាមសាច់ដុំភ្លៅ ឬសាច់ដុំដៃ អាស្រ័យលើអាយុរបស់កុមារ ។ វាអាចចាក់បានក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការដទៃទៀតដែរ ។

**កុមារ**

កុមារត្រូវចាក់ថ្នាំបង្ការ IPV ចំនួន 4 ដូស ក្នុងចំណោមអាយុដូចខាងក្រោម ៖

- ចាក់មួយដូស ពេលអាយុ 2 ខែ
- ចាក់មួយដូស ពេលអាយុ 4 ខែ
- ចាក់មួយដូស ពេលអាយុ 6-18 ខែ
- ចាក់ដូសរំឭកពេលអាយុ 4-6 ឆ្នាំ

**មានថ្នាំបង្ការខ្លះ** “ដាក់បញ្ចូលគ្នា” (ថ្នាំបង្ការបី បួនមុខចូលគ្នា ចាក់តែមួយដង) ជាមួយនឹងថ្នាំបង្ការ IPV ។

កុមារដែលចាក់ថ្នាំបង្ការទាំងនេះ អាចត្រូវចាក់មួយដូស (ដូសទី 5) ទៀតនៃថ្នាំបង្ការជំងឺស្វិតដៃជើង ។ នេះមិនមែនជាបញ្ហា ទេ ។

**មនុស្សចាស់**

មនុស្សចាស់ដែលមានអាយុ 18 ឆ្នាំ និងចាស់ជាងនេះ មិនចាំបាច់ចាក់ថ្នាំបង្ការជំងឺស្វិតដៃជើងឡើយ ពីព្រោះថា ពួកគេបានទទួលថ្នាំនេះរួចហើយកាលពីពួកគេនៅតូច ។ តែមានមនុស្សចាស់ខ្លះ ស្ថិតក្នុងហានិភ័យខ្ពស់ ហើយគួរពិចារណាចាក់ថ្នាំបង្ការជំងឺស្វិតដៃជើង ដូចតទៅ ៖

(1) អ្នកដែលធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗនៃពិភពលោក ដែលនៅមានជំងឺស្វិតដៃជើងនៅឡើយ

(2) បុគ្គលិកមន្ទីរពិសោធន៍ ដែលអាចប្រឈមជាមួយនឹងវីរុសជំងឺស្វិតដៃជើង និង

(3) បុគ្គលិកថែទាំសុខភាព ព្យាបាលអ្នកជំងឺដែល អាចកើតជំងឺស្វិតដៃជើង ។

មនុស្សចាស់ ដែលស្ថិតក្នុងចំណោមក្រុមទាំងបីនេះ ៖

- អ្នកដែលមិនធ្លាប់បានចាក់ថ្នាំបង្ការជំងឺស្វិតដៃជើងពីមុនមក គួរតែចាក់ថ្នាំបង្ការ IPV ចំនួន 3 ដូស ៖
  - ពីរដូស ដែលឃ្លាតពីគ្នាចំនួន 1 ទៅ 2 ខែ និង
  - ដូសទីបី ឃ្លាតពីគ្នា 6 ទៅ 12 ខែ បន្ទាប់ពីដូសទីពីរ ។
- អ្នកដែលបានចាក់ថ្នាំបង្ការ **1 ឬ 2 ដូស** កាលពីមុន

គួរតែទទួលដូសដែលនៅសល់ 1 ឬ 2 ដូសដែលនៅសល់ ។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

វាមិនសំខាន់ទេចំពោះរយៈពេលដែលចាក់ដូសពីដំបូងនោះ ។

- អ្នកដែលបានទទួលថ្នាំបង្ការជំងឺស្វិតដៃជើង 3 ដូស ឬច្រើនជាងនេះកាលពីពេលមុន អាចត្រូវចាក់ IPV រំឭកមួយដូសទៀត ។

គ្រូពេទ្យរបស់អ្នក អាចផ្តល់ព័ត៌មានបន្ថែមដល់អ្នក ។

## 4 អ្នកខ្លះ មិនគួរចាក់ថ្នាំបង្ការ IPV ឬគួររង់ចាំសិន

**អ្នកទាំងនេះ មិនគួរចាក់ថ្នាំ IPV ឡើយ ៖**

- អ្នកណាម្នាក់ដែលមានប្រតិកម្មខ្លាំងក្លា ចំពោះសមាសធាតុថ្នាំបង្ការណាមួយនៃ IPV រួមទាំងថ្នាំ អង់ទីប៊ីយ៉ូទិក ស្ត្រិបតូមីស៊ីន ឬប៉ូលីមីស៊ីនB មិនគួរចាក់ថ្នាំបង្ការជំងឺស្វិតដៃជើងឡើយ ។ សូមប្រាប់ឲ្យគ្រូពេទ្យរបស់អ្នកឲ្យបានដឹង បើអ្នកមាន ប្រតិកម្មជាតុធ្ងន់ធ្ងរណាមួយ ។
- អ្នកណាដែលមានប្រតិកម្មបញ្ច្រាសទិសធ្ងន់ធ្ងរ ចំពោះការចាក់ថ្នាំបង្ការជំងឺស្វិតដៃជើងកាលពី មុន មិនគួរចាក់ម្តងទៀតឡើយ ។

**អ្នកទាំងនេះ គួររង់ចាំសិន ៖**

នរណាម្នាក់ដែលមានជម្ងឺមធ្យម ឬធ្ងន់ធ្ងរ ក្នុងពេលត្រូវចាក់ថ្នាំនេះ ជាធម្មតាគួររង់ចាំឲ្យជំងឺ ជាសិន ទើបអាចចាក់ថ្នាំបង្ការស្វិតដៃជើងនេះបាន ។ អ្នកឈឺតិចតួច ដូចជាផ្តាសាយ អាចចាក់ថ្នាំនេះបាន ។

សួរគ្រូពេទ្យរបស់អ្នក សម្រាប់ព័ត៌មានបន្ថែម ។

## 5 តើមានហានិភ័យអ្វីចំពោះថ្នាំបង្ការ IPV?

អ្នកខ្លះដែលចាក់ថ្នាំ IPV មានការឈឺចាប់ត្រង់បរិវេណចាក់ម្ជុល ។ គេនៅមិនទាន់បានដឹងនៅឡើយទេថា ថ្នាំបង្ការ IPV អាចបង្ករជាបញ្ហាធ្ងន់ធ្ងរ ហើយមនុស្សភាគច្រើន ដែលចាក់ថ្នាំនេះ មិនដែលមានបញ្ហាអ្វី កើតឡើងនោះទេ ។

ទោះជាយ៉ាងណាក៏ដោយ ថ្នាំទាំងអស់សុទ្ធតែអាចបង្ករផលវិបាកធ្ងន់ធ្ងរបាន ដូចជាប្រតិកម្ម បញ្ច្រាសទិសធ្ងន់ធ្ងរ ឬអាចបណ្តាលឲ្យស្លាប់បាន ។ ហានិភ័យពីថ្នាំបង្ការជំងឺស្វិតដៃជើង ដែលបង្ករឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរមានកំរិតតិចតួចណាស់ ។

## 6 ចុះប្រសិនបើមានបញ្ហាមធ្យម ឬធ្ងន់ធ្ងរកើតឡើង ត្រូវធ្វើដូចម្តេច?

**តើខ្ញុំគួររកមើលអ្វី?**

- ចូររកមើលស្ថានភាពណាដែលខុសប្រក្រតី ដូចជាប្រតិកម្មបញ្ច្រាសទិសធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬអាកប្បកិរិយាខុសប្រក្រតី ។

ប្រសិនបើមានប្រតិកម្មបញ្ច្រាសទិសធ្ងន់ធ្ងរកើតឡើង វានឹងកើតឡើងក្នុងរវាងពីរបីនាទី ទៅពីរបីម៉ោង បន្ទាប់ពីចាក់រួច ។ សញ្ញានៃប្រតិកម្មបញ្ច្រាសទិសធ្ងន់ធ្ងរ មានដូចជា ពិបាកដកដង្ហើមខ្សោយកម្លាំង ដកដង្ហើមឮងឺតៗ ឬរ៉ឺតៗ បេះដូងដើរញាប់ ឡើងបន្ទាលត្រអាក វិលមុខ ស្លេក ឬ ហើមបំពង់ក ។

**តើខ្ញុំគួរធ្វើអ្វី?**

- **ហៅទូរស័ព្ទមកជួបគ្រូពេទ្យ** ឬបញ្ជូនអ្នកជំងឺ មកជួបគ្រូពេទ្យជាបន្ទាន់ ។
- ប្រាប់គ្រូពេទ្យរបស់អ្នកពីអ្វីដែលបានកើតឡើង កាលបរិច្ឆេទ និងពេលវេលាដែលបានកើតឡើង និងពេលដែលអ្នកជំងឺបានទទួលការចាក់ថ្នាំ បង្ការ ។
- ប្រាប់ដល់អ្នកផ្តល់សេវាឲ្យអ្នក ធ្វើរបាយការណ៍ ពីប្រតិកម្ម បញ្ច្រាសទិសដោយការបំពេញសំណុំ បែបបទ Vaccine Adverse Event Reporting System (VAERS-ប្រព័ន្ធការធ្វើ របាយការណ៍ហេតុការណ៍ប្រតិកម្មបញ្ច្រាស់ទិសរបស់ថ្នាំ បង្ការ) ។

  ឬអ្នកក៏អាចរាយការណ៍អំពីរឿងនេះ តាមរយៈ គេហទំព័ររបស់ VAERS តាមរយៈអាសយដ្ឋាន **www.vaers.hhs.gov** ឬដោយការហៅទូរស័ព្ទ មកកាន់លេខ **1-800-822-7967** ។

  *VAERS* មិនផ្តល់ជូនព័ត៌មានវេជ្ជសាស្ត្រ ឡើយ ។

## 7 កម្មវិធីផ្តល់សំណងរបួសស្នាមបណ្តាល ពីថ្នាំបង្ការ?

National Vaccine Injury Compensation Program (VICP-កម្មវិធីជាតិផ្តល់សំណង របួសស្នាមបណ្តាលពីថ្នាំបង្ការ) ត្រូវបាន បង្កើតឡើងក្នុងឆ្នាំ 1986 ។

អ្នកដែលជឿជាក់ថាខ្លួនអាចមានរបួសស្នាម បណ្តាលពីថ្នាំបង្ការ អាចអានឲ្យបានដឹងពី កម្មវិធីផ្តល់សំណង និងរបៀបដាក់ពាក្យទារសំណង ដោយការហៅទូរស័ព្ទមកកាន់លេខ **1-800-338-2382** ឬទស្សនាគេហទំព័ររបស់ VICP ដែលមានអាសយដ្ឋាន **www.hrsa.gov/vaccinecompensation** ។

## 8 តើខ្ញុំអាចបានដឹងព័ត៌មានបន្ថែមដោយរបៀបណា?

- សួរគ្រូពេទ្យរបស់អ្នក ។ ពួកគេអាច អាចផ្តល់ឲ្យអ្នកនូវកញ្ចប់ព័ត៌មានថ្នាំបង្ការ ដល់អ្នក ឬប្រាប់អ្នកពីប្រភពព័ត៌មានផ្សេងទៀតដល់អ្នក ។
- ចូរហៅទូរស័ព្ទទៅកាន់នាយកដ្ឋានសុខាភិបាលប្រចាំតំបន់ ឬនាយកដ្ឋានសុខាភិបាលប្រចាំរដ្ឋរបស់អ្នក ។
- ចូរទាក់ទងជាមួយនឹង Centers for Disease Control and Prevention (CDC-មជ្ឈមណ្ឌល គ្រប់គ្រង និងការពារជំងឺ) ៖
  - ហៅមកលេខ **1-800-232-4636 (1-800-CDC-INFO)** ទស្សនាគេហទំព័ររបស់ CDC តាមរយៈអាសយដ្ឋាន **www.cdc.gov/vaccines**


Vaccine Information Statement (Interim)

Polio Vaccine

Cambodian

11/8/2011

42 U.S.C. § 300aa-26

Translation provided by the California Department of Public Health